D119571 DC-Cam

# **របាយការណ៍ផែនទីខេត្តកំពង់ឆ្នាំង**

# **"ឆ្នាំ ១៩៩៩ ខែ មិថុនា"**

**ដោយ : វ៉ាន់ថាន់ ពៅដារ៉ា**

នៅព្រឹកថ្ងៃទី ៩ មិថុនា ឆ្នាំ ១៩៩៩ មានក្រុមផែនទីមួយក្រុម ដែលមានសមាសភាព ៤ រូប គឺ លោក ស៊ិន ឃិន ជាអ្នកទំនាក់ទំនងជាមួយអជ្ញាធរមូលដ្ឋាន និងធ្វើការសំភាស លោក **អ៊ុច សំអឿន** ជាអ្នកច្នេក ទេសប្រើម៉ាស៊ីន GPS លោក ពៅ ដារ៉ា ជាអ្នកសំភាសសាក្សី និងអ្នកធ្វើរបាយការណ៍ និងលោក **រស់ សំពៅ** ជាអ្នកគូរប្លង់ទីតាំងប្រល័យពូជសាសន៍ ។

ក្រុមនេះបានចេញដំណើរពីភ្នំពេញ មកកាន់ខេត្តកំពង់ឆ្នាំង តាមផ្លូវជាតិលេខ ៥ ដោយរថយន្ត ។ ចេញពីភ្នំពេញបានប្រហែល ៥០គីឡូម៉ែត្រ យើងបត់ចូលទៅស្នាក់ការស្រុកសាមគ្គីមានជ័យ ដែលនៅខាងឆ្វេងដៃតាមផ្លូវលំ ចំងាយប្រហែល ១២គីឡូម៉ែត្រ ពីផ្លូវជាតិលេខ ៥ ។ ក្រុមនេះបានទៅដល់ទីស្នាក់ការស្រុកនៅវេលាម៉ោង ៩:៣០នាទីព្រឹក ដោយថែមទាំងបានជួបធ្វើការងារទាក់ទងអំពីរឿងទីតាំងប្រល័យពូជសាសន៍ទៀតផង ជាមួយនឹងលោកអភិបាលស្រុក ឈ្មោះ **ឈួន ឃឿន** អាយុ ៤៨ ឆ្នាំ និងលោកអភិបាលរងឈ្មោះ **ចាន់ ថឿន** អាយុ ៤៤ ឆ្នាំ ។ លោកអភិបាលស្រុកសាមគ្គីមានជ័យ **ឈួន ឃឿន** បានមានប្រសាសន៍ថា : ស្រុកនេះជា ស្រុកទើបកកើតថ្មី ដែលបំបែកចេញពីស្រុកកំពង់ត្រឡាច នៅខែ ១២ ឆ្នាំ ១៩៨៥ ។

គោលការណ៍ធំបំផុតដែលត្រូវបំបែកទៅជាស្រុកថ្មីនេះ គឺទប់ទល់នឹងការឃាយ៉ីមកលើប្រជាជនក្នុងតំបន់នេះដោយពួកខ្មែរក្រហម ។ ដោយទីតាំងស្រុកនេះជាប់នឹងផ្លូវរទេះភ្លើងផងនោះ ដើម្បីការពារផ្លូវដែកកុំអោយពួកខ្មែរក្រហមធ្វើការវាយប្រហារជាគោលការណ៍ចំបងទី២ ។ ប៉ុន្តែសភាពការណ៍តានតឹងក្នុងពេលនោះ ត្រូវបានធូរស្រាលជាស្ថាពរឡើងវិញនៅក្រោយមានសមាហរណកម្មចុងក្រោយរបស់ពួកខ្មែរក្រហម និងនៅមុនកៀកពេលបោះឆ្នោត ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។

រហូតមកដល់បច្ចុប្បន្ន ស្រុកសាមគ្គីមានជ័យ ចែកចេញជា ៩ឃុំ និង៨៥ភូមិ ជាមួយនិងប្រជាជនសរុបប្រមាណ ៦០.៤៨៩ នាក់ ក្នុងនោះមានស្រី ៣១.៩៨៩ នាក់ ហើយត្រូវនឹង ១២.១៤៤គ្រួសារ ។ លោកអភិបាលបន្តទៀតថា ប្រជាជននៅទីនេះភាគច្រើនប្រកបរបរធ្វើស្រែជារបរចំបង ក្រៅពីនោះគឺប្រកបរបរឡើងត្នោត ដាំដំណាំបន្ទាប់បន្សំដូចជា សណ្តែកដី ឪឡឹក ជាដើម ...........។ ឆ្លៀតឱកាសនោះយើងបានសួរលោកអភិបាល ចំពោះរឿងរ៉ាវផ្ទាល់ខ្លួនរបស់លោកក្នុងរបបខ្មែរក្រហម ។ លោកអភិបាលស្រុក **ឈួន ឃឿន** រាប់រៀបថា ក្នុងជំនាន់ប៉ុលពត មុនដំបូងលោករស់នៅឃុំអំពិលទឹក ស្រុកកំពង់

ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ក្នុងឆ្នាំ១៩៧៧ គាត់ផ្លាស់ទៅ ភូមិព្រៃខ្មែរ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលកាលណោះ គាត់ធ្វើជាកងចល័តតំបន់ ៣១ ។ **លោក ឃឿន** និយាយថាការងារកងចល័តគឺការងារលើកដី ជីកប្រឡាយ និងលើកទំនប់ ។ទាក់ទងនឹងការកាប់សំលាប់របស់ពួកខ្មែរក្រហម លោកនិយាយថា ពួកកងចល័តភាគច្រើនមិនសូវដឹងរឿងរ៉ាវអស់នេះទេ ហើយគាត់ផ្ទាល់ធ្លាប់ឃើញពេលប្រជុំម្តងម្កាល កាត់ទោសពួកកងចល័ត ២ ឬ ៣ នាក់ ហើយយកទៅវាយចោល តែភាគច្រើនពួកខ្មែរក្រហមច្រើនសំលាប់ប្រជាជនធម្មតាក្នុងសហករណ៍ ដូចជាខ្លួនគាត់មាន ឪពុកម្តាយ បងបង្កើត ៣នាក់ ក្មួយ ៣នាក់ រស់នៅក្នុងសហករណ៍អំពិលទឹក ត្រូវខ្មែរក្រហមសំលាប់ក្នុងឆ្នាំ ១៩៧៦ ។

ដើម្បីអោយដឹងរឿងនេះច្បាស់ថែមទៀត លោកអភិបាលបានហៅលោក **គីម ពន** ដែលជាអនុប្រធានការិយាល័យកសិកម្មស្រុក អោយយើងបានសំភាសជាមួយ ព្រោះឈ្មោះ **គីម ពន** នេះធ្លាប់ជាជនរងគ្រោះ ហើយបានជួបប្រទះរឿងរ៉ាវច្រើនក្នុងរបបខ្មែរក្រហម ។

លោក **គីម ពន** អាយុ ៤៨ឆ្នាំ មានស្រុកកំណើតនៅ ភូមិក្រាំងស្រម៉ ឃុំស្វាយជុក ស្រុកកំពង់ត្រឡាច (បច្ចុប្បន្នស្រុកសាមគ្គីមានជ័យ) ខេត្តកំពង់ឆ្នាំង ។ **គីម ពន** ធ្លាប់ធ្វើជាប្រធានកងចល័តស្រែប្រាំង ក្នុងឆ្នាំ ១៩៧៦ នៅ ភូមិក្រាំងស្រម៉ ឃុំស្វាយជុក ស្រុក១២ ដែលក្រោយមកក្នុងរវាងចន្លោះខែ ៤ ឆ្នាំ១៩៧៧ ដល់ខែ ១០ ឆ្នាំ ១៩៧៨ គាត់ត្រូវបានខ្មែរក្រហមនេះ ចាប់គាត់យកទៅដាក់គុកសន្តិសុខស្រុក១២ ដែលគុកនេះត្រូវហៅថាជា **គុកព្រៃដីស្រុត** ស្ថិតក្នុងភូមិដីស្រុត ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ មូលហេតុដែលគាត់ត្រូវជាប់គុក ដោយសារគាត់បានជួយសង្គ្រោះប្រជាជន ១៧មេសា ដោយគាត់ឱ្យគេដាំបាយអោយពួកនេះហូប ។ គាត់និយាយថា គាត់មិនត្រូវបានពួកខ្មែរក្រហមបង្ខំអោយធ្វើការទេ ហើយក៏មិនទទួលទារុណកម្មអ្វីដែរ ។ ទោសនេះជាទោសស្រាលដែលពួកខ្មែរក្រហមគ្រាន់តែបង្ខំអោយរែកដីប៉ុណ្ណោះ ។ អតីតប្រធានកងចល័តធ្វើស្រែប្រាំង **គីម ពន** បានបញ្ជាក់ថាអ្នកជាប់ទោសត្រូវបានខ្មែរក្រហមចែកចេញពីរប្រភេទ ដែលប្រភេទទី១ គេហៅថា ទោសស្រាល និងប្រភេទទី២ គឺទោសធ្ងន់ ។ អ្នកទោសដែលគេចាត់ទុកថាមានទោសស្រាល គឺប្រភេទអ្នកទោសដែលមានកំហុសក្នុងការដាំស្រូវខុសពូជស្រូវ ដែលអង្គការតំរូវបណ្តោយអោយគោស៊ីស្រូវជាដើម ។ អ្នកទោសប្រភេទនេះ គឺពុំតំរូវអោយនៅក្នុងអាគារគុកទេ គឺនៅក្រៅគុក ហើយពុំមានដាក់ខ្នោះឡើយ ។ ឯចំណែកអ្នកទោសដែលត្រូវចាត់ទុកថាមានទោសធ្ងន់ គឺតំរូវឱ្យធ្វើការងារធ្ងន់ ហើយពេលចេញទៅធ្វើការត្រូវជាប់ទាំងខ្នោះជើង ដែលពួកអ្នកធ្វើការក្នុងគុក (កងសន្តិសុខ) ច្រើននិយាយថា " **ពួកគោដីរមកហើយ** " ។ បានជាពួកវាថាយ៉ាងដូច្នេះ ព្រោះអ្នកទោសធ្ងន់ដែលជាប់ទាំងខ្នោះជើងដើរទៅធ្វើការដូចជាជើងដីរ ដោយសារតែជើងទាំងពីរជាប់ខ្នោះ ហើយចន្លោះពីជើងមួយ ទៅជើងមួយទៀត មានទំហំប៉ុនជើងដីរ ។ អ្នកទោសធ្ងន់ត្រូវធ្វើការគ្មានពេលសំរាក ហើយពេលដល់ម៉ោងចូលគុកវិញ ពួកគេត្រូវបានសំរាកដោយជើង

ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ក្នុងឆ្នាំ១៩៧៧ គាត់ផ្លាស់ទៅ ភូមិព្រៃខ្មែរ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលកាលណោះ គាត់ធ្វើជាកងចល័តតំបន់ ៣១ ។ **លោក ឃឿន** និយាយថាការងារកងចល័តគឺការងារលើកដី ជីកប្រឡាយ និងលើកទំនប់ ។ទាក់ទងនឹងការកាប់សំលាប់របស់ពួកខ្មែរក្រហម លោកនិយាយថា ពួកកងចល័តភាគច្រើនមិនសូវដឹងរឿងរ៉ាវអស់នេះទេ ហើយគាត់ផ្ទាល់ធ្លាប់ឃើញពេលប្រជុំម្តងម្កាល កាត់ទោសពួកកងចល័ត ២ ឬ ៣ នាក់ ហើយយកទៅវាយចោល តែភាគច្រើនពួកខ្មែរក្រហមច្រើនសំលាប់ប្រជាជនធម្មតាក្នុងសហករណ៍ ដូចជាខ្លួនគាត់មាន ឪពុកម្តាយ បងបង្កើត ៣នាក់ ក្មួយ ៣នាក់ រស់នៅក្នុងសហករណ៍អំពិលទឹក ត្រូវខ្មែរក្រហមសំលាប់ក្នុងឆ្នាំ ១៩៧៦ ។

ដើម្បីអោយដឹងរឿងនេះច្បាស់ថែមទៀត លោកអភិបាលបានហៅលោក **គីម ពន** ដែលជាអនុប្រធានការិយាល័យកសិកម្មស្រុក អោយយើងបានសំភាសជាមួយ ព្រោះឈ្មោះ **គីម ពន** នេះធ្លាប់ជាជនរងគ្រោះ ហើយបានជួបប្រទះរឿងរ៉ាវច្រើនក្នុងរបបខ្មែរក្រហម ។

លោក **គីម ពន** អាយុ ៤៨ឆ្នាំ មានស្រុកកំណើតនៅ ភូមិក្រាំងស្រម៉ ឃុំស្វាយជុក ស្រុកកំពង់ត្រឡាច (បច្ចុប្បន្នស្រុកសាមគ្គីមានជ័យ ) ខេត្តកំពង់ឆ្នាំង ។ **គីម ពន** ធ្លាប់ធ្វើជាប្រធានកងចល័តស្រែប្រាំង ក្នុងឆ្នាំ ១៩៧៦ នៅ ភូមិក្រាំងស្រម៉ ឃុំស្វាយជុក ស្រុក១២ ដែលក្រោយមកក្នុងរវាងចន្លោះខែ ៤ ឆ្នាំ១៩៧៧ ដល់ខែ ១០ ឆ្នាំ ១៩៧៨ គាត់ត្រូវបានខ្មែរក្រហមនេះ ចាប់គាត់យកទៅដាក់គុកសន្តិសុខស្រុក១២ ដែលគុកនេះត្រូវហៅថាជា **គុកព្រៃដីរស្រុត** ស្ថិតក្នុងភូមិដីរស្រុត ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ មូលហេតុដែលគាត់ត្រូវជាប់គុក ដោយសារគាត់បានជួយសង្គ្រោះប្រជាជន ១៧មេសា ដោយគាត់ឱ្យគេដាំបាយអោយពួកនេះហូប ។ គាត់និយាយថា គាត់មិនត្រូវបានពួកខ្មែរក្រហមបង្ខំអោយធ្វើការទេ ហើយក៏មិនទទួលទារុណកម្មអ្វីដែរ ។ ទោសនេះជាទោសស្រាលដែលពួកខ្មែរក្រហមគ្រាន់តែបង្ខំអោយរែកដីប៉ុណ្ណោះ ។ អតីតប្រធានកងចល័តធ្វើស្រែប្រាំង **គីម ពន** បានបញ្ជាក់ថាអ្នកជាប់ទោសត្រូវបានខ្មែរក្រហមចែកចេញពីរប្រភេទ ដែលប្រភេទទី១ គេហៅថា ទោសស្រាល និងប្រភេទទី២ គឺទោសធ្ងន់ ។ អ្នកទោសដែលគេចាត់ទុកថាមានទោសស្រាល គឺប្រភេទអ្នកទោសដែលមានកំហុសក្នុងការដាំស្រូវខុសពូជស្រូវ ដែលអង្គការតំរូវបណ្តោយអោយគោស៊ីស្រូវជាដើម ។ អ្នកទោសប្រភេទនេះ គឺពុំតំរូវអោយនៅក្នុងអាគារគុកទេ គឺនៅក្រៅគុក ហើយពុំមានដាក់ខ្នោះឡើយ ។ ឯចំណែកអ្នកទោសដែលត្រូវចាត់ទុកថាមានទោសធ្ងន់ គឺតំរូវឱ្យធ្វើការងារធ្ងន់ ហើយពេលចេញទៅធ្វើការត្រូវជាប់ទាំងខ្នោះជើង ដែលពួកអ្នកធ្វើការក្នុងគុក (កងសន្តិសុខ) ច្រើននិយាយថា " **ពួកកងដីរមកហើយ** "។ បានជាពួកវាថាយ៉ាងដូច្នេះ ព្រោះអ្នកទោសធ្ងន់ដែលជាប់ទាំងខ្នោះជើងដើរទៅធ្វើការដូចជាជើងដីរ ដោយសារតែជើងទាំងពីរជាប់ខ្នោះ ហើយចន្លោះពីជើងមួយ ទៅជើងមួយទៀត មានទំហំប៉ុនជើងដីរ ។ អ្នកទោសធ្ងន់ត្រូវធ្វើការគ្មានពេលសំរាក ហើយពេលដល់ម៉ោងចូលគុកវិញ ពួកគេត្រូវបានសំរាកដោយជើង

ជាប់ខ្នោះ ហើយដេកដាក់ជើងដែលជាប់ខ្នោះ ទល់ជើងគ្នាជាជួរ ។ អ្នកទោសធ្ងន់ ភាគច្រើនជា ទាហ៊ាន គិញ្ញ រាជការសម័យសីហនុ និង លន់ណុល ។ ក្រៅពីនោះ គឺសុទ្ធតែជាគ្រូបង្រៀននិងអ្នកទោសដែលមាន កំហុសស្រាល ហើយមានកំហុសថែមទៀត ក្នុងពេលជាប់ឃុំ ដោយពួកអ្នកគុកចោទ ។

**គីម ពន** បាននិយាយទៀតថា ក្នុងគុកនោះមានអ្នកទោសទាំងក្មេង ទាំងចាស់ ហើយនិងកូនក្មេងដែលវាទៅជាមួយឪពុកម្តាយវា ដែលត្រូវខ្មែរក្រហមចាប់ ។ អ្នកទោសក្នុងគុកព្រៃដីវស្រុត ភាគតិចទេដែលត្រូវខ្មែរក្រហមយកទៅសំលាប់ ។ ក្រៅពីនោះគឺត្រូវស្លាប់ដោយអត់បាយ ខ្លះដេកស្លាប់ក្នុងគុកដោយជើងជាប់ខ្នោះ និង ខ្លះទៀតត្រូវពួកខ្មែរក្រហមបង្ខំអោយធ្វើការងារធ្ងន់រហូតទាល់ស្លាប់ក៏មាន ។ សាកសពទាំងអស់នេះ ពួកខ្មែរក្រហមបញ្ជារអោយអ្នកទោសយកទៅកាត់ជាកង់ៗ ដែលក្នុងសាកសពម្នាក់កាត់ជា ២កង់ ហើយយកកង់ៗនៃសាកសពនោះទៅដាក់អន្លង់ដាំដំឡូង និងអន្លង់ដាំដើមដូង ។

**គីម ពន** ដែលធ្លាប់ជាអ្នកទោសស្រាលនៅក្នុង **គុកព្រៃដីវស្រុត** បានបន្ថែមថា ចំពោះអ្នកទោសស្រាលដូចរូបគាត់ត្រូវចេញទៅធ្វើការនៅម៉ោង ៦ព្រឹក តែត្រូវភ្ញាក់តាំងពីម៉ោង ៥ព្រឹក តាមស្នូរវ៉ាយអាគាំងរបស់ពួកសន្តិសុខគុក ហើយសំរាកនៅម៉ោង ១២ថ្ងៃត្រង់ ដើម្បីហូបបបរវាវ ។ សំរាករយៈពេល ១ម៉ោង ក៏បន្តរធ្វើការតទៅទៀត រហូតដល់ម៉ោង ៥ល្ងាច ទើបត្រឡប់មកកន្លែងគុកវិញ ។ បើសិនជាត្រូវខែភ្លឺអ្នកទោសត្រូវធ្វើការទាំងយប់ ហើយបើដល់ពេលស្ទូងរួចរាល់ហើយ អ្នកទោសត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ។ តាមការឆ្លើយបំភ្លឺរបស់ **ពន** ថា ពួកសន្តិសុខមានកាន់កាំភ្លើង និងរំពាត់វែងៗផងពេលបណ្តើរទៅធ្វើការម្តងៗ ហើយពួកសន្តិសុខគុកទាំងអស់មានគ្នាប្រហែល ១២នាក់ ដែលត្រូវចែកជាពីរក្រុម គឺក្រុមសំរាប់អ្នកទោសធ្ងន់ និងក្រុមសំរាប់អ្នកទោសស្រាល ។ ប្រធានគុកនៅទីនោះ ឈ្មោះ **អែម** ដែលតាម **គីម ពន** ថា ប្រហែលជាស្លាប់ ឈ្មោះ **អុល** សព្វថ្ងៃ នៅភូមិច្រេស ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង **សួន** ជាឃាតករ និងជាអ្នកសួរចំលើយ ត្រូវស្លាប់ក្នុងពេលដែលខេត្តកំពង់ឆ្នាំងត្រូវបានរំដោះនៅឆ្នាំ ១៩៧៩ ពីរបបខ្មែរក្រហម ដោយប្រជាជនក្នុងភូមិសំលាប់សងសឹក ។

**គីម ពន** បានប្រាប់យើងថា មនុស្សជាប់គុកដូចរូបគាត់ ដែរនៅគុកព្រៃដីវ ហើយដែលរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះមាន : **ម៉ាត ម៉ូត** អភិបាលស្រុកកំពង់ត្រឡាច តា **អ៊ុន** និង **ស៊ីម** នៅឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ចុងក្រោយ **ពន** បាននិយាយដោយទឹកមុខញញឹមថា គាត់នឹងស្ម័គ្រចិត្ត ចូលធ្វើសាក្សីបំភ្លឺនៅមុខតុលាការ ប្រសិនបើត្រូវការគាត់ធ្វើយ៉ាងដូច្នេះ ។ ក្នុងថ្ងៃនោះបន្ទាប់ពីបញ្ចប់ការសំភាសន៍នេះមក យើងមិនបានចុះទៅកន្លែង ឬទីតាំងប្រល័យពូជសាសន៍ទេ ដោយសារតែទីតាំងនោះស្ថិតនៅឆ្ងាយពីស្នាក់ការសាលាស្រុកសាមគ្គីមានជ័យ ។ ម្យ៉ាងទៀតផ្លូវដែលត្រូវទៅទីតាំងប្រល័យពូជសាសន៍ មិនអាចចេញពីសាលាស្រុកតែម្តងទេ គឺត្រូវធ្វើដំណើរតាមឡានទៅរកផ្លូវផ្សេងមួយទៀត ដែលតាមការចង្អុលបង្ហាញ និងប្រាប់ជាប្លង់ផែនទី គឺផ្លូវលំជាប់នឹងរបងវត្ត **ក្រុលម្តត័ន្ត** ។ ដូច្នេះ

នៅម៉ោងប្រហែល ២ថ្ងៃត្រង់ យើងក៏បានចាកចេញពីសាលាស្រុកសាមគ្គីមានជ័យឆ្ពោះទៅកាន់ទីរួមខេត្តកំពង់ឆ្នាំងតែម្តង ដើម្បីត្រៀមលក្ខណៈសំរាប់ថ្ងៃស្អែក និងចុះទៅអោយដល់ទីតាំងប្រល័យពូជសាសន៍ក្នុងភូមិជំទាវជ្រៃង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ក្នុងខេត្តកំពង់ឆ្នាំង ។ ដូចដែលក្រុមផែនទីយើងបានគិតទុកជាមុន នៅព្រឹកថ្ងៃទី ១០ ខែឆ្នាំដដែល ម៉ោងប្រហែលជាង ៦ ក្រុមយើងបានធ្វើដំណើរចេញពីទីរួមខេត្តកំពង់ឆ្នាំង ឆ្ពោះមករកផ្លូវច្រកចូលទៅភូមិជំទាវជ្រៃង ។ យើងធ្វើដំណើរប្រហែលជាង១ម៉ោងក៏បានមកដល់ច្រកផ្លូវចូលទៅភូមិជំទាវជ្រៃង ដែលនៅជាប់នឹងរបង **វត្តកុលម្ពត័ន្ត** ហើយចំពោះការធ្វើដំណើរបត់បែនយ៉ាងណាៗនោះ សូមមើលតាមគំនូសសញ្ញាដែលលោក **រស់ សំពៅ** បានគូសភ្ជាប់មកជាមួយក្នុងរបាយការណ៍នេះដែរ ។

ក្នុងចន្លោះផ្លូវពីច្រកចូលទៅភូមិ ដែលនៅជាប់របងវត្ត រហូតដល់ភូមិតែម្តងនោះ យើងបានជួបលោកអភិបាលរងស្រុកសាមគ្គីមានជ័យ ដែលលោកបានរង់ចាំយើងនៅផ្ទះរបស់លោកផ្ទាល់ជាស្រេច ។ ពេលយើងជួបនឹងគាត់ គាត់បានស្វាគមន៍ពួកយើង ហើយជូនពួកយើងទៅរកជួបប្រធានភូមិ និងសាក្សីដែលធ្លាប់ស្គាល់ទីតាំងប្រល័យពូជសាសន៍ក្នុងភូមិជំទាវជ្រៃង ។ ក្នុងពេលនោះដែរក្នុងឋានៈអភិបាលស្រុករង លោក **ចាន់ ធឿន** បានអញ្ជើញកំលាំងជាវពលភូមិ និងនគរបាលភូមិ រួមដំណើរជាមួយក្រុមយើងដែរដើម្បីទៅអោយដល់ទីតាំងប្រល័យពូជសាសន៍ ។ ទំរាំដល់ទីតាំងប្រល័យពូជសាសន៍ យើងទាំងអស់គ្នាបានធ្វើដំណើរដោយជិះឡានកាត់ព្រៃ កាត់អូរ ចំនួនពីរ និងមានផ្លូវបត់បែនច្រើនរាប់មិនអស់ ។ ប្រសិនបើគ្មានអ្នកភូមិនាំយើងទៅទេ យើងមិនអាចរកទីតាំងនោះឃើញឡើយ ទោះបីជាយើងធ្លាប់ទៅរួចហើយក៏ដោយ ។ ពេលដល់អូរទី២ យើងឈប់ឡានទីនោះ រួចយើងបន្តដំណើរប្រហែលជា ២គីឡូម៉ែត្រដោយថ្មើរជើងចូលក្នុងព្រៃក្រាស់ទៀត ទើបដល់ទីតាំងដែលយើងចង់រក ។ ទីតាំងប្រល័យពូជសាសន៍ដែលយើងបានទៅដល់មានឈ្មោះថា **ព្រៃត្រពាំងអំពិល** ( ទាំងអ្នកជូនដំណើរ ដូចជាប្រធានកងជីវពលភូមិ ទាំងសាក្សីប្រាប់យ៉ាងដូច្នេះ ) ។ នៅត្រង់ទីតាំងនោះ យើងបានដើរមើលរណ្តៅសាកសពដែលសាក្សីចង្អុលបង្ហាញដែលស្ថិតនៅក្នុងព្រៃក្រាស់ និង មានសភាពស្មើររលប់ទៅជាដីស្មើ ។ តាមការប៉ាន់ស្មានរបស់សាក្សី ទីតាំងនេះមានទំហំដីប្រហែល ២ហិកតា និងមានរណ្តៅប្រមាណជាង៥០០ ដែលក្នុងរណ្តៅនីមួយៗមានសាកសពប្រហែលពី ២០ ទៅ ៥០នាក់ ។

**<u>សាក្សីទី១</u> :**

ឈ្មោះ **ប៊ិន ម៉េត** ភេទ ប្រុស អាយុ ៥៩ ឆ្នាំ អតីត មេភូមិជំទាវជ្រៃង ក្នុងឆ្នាំ ១៩៧០-១៩៧៥ ។ ទាំងជំនាន់ប៉ុលពត ទាំងបច្ចុប្បន្ន គាត់រស់នៅក្នុងភូមិជំទាវជ្រៃង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ បច្ចុប្បន្នជាប្រធានគណៈកម្មការវត្តក្រាំងល្វា ក្នុងឃុំនេះ ។ **ប៊ិន ម៉េត** និយាយថា

ទីតាំងប្រល័យពូជសាសន៍ ត្រូវបានគេហៅថា **ព្រៃត្រពាំងអំពិល** ហើយជុំវិញកន្លែងនេះ គេចាត់ទុកជាតំបន់ចំរុះ ព្រោះថាជនរងគ្រោះដោយខ្មែរក្រហមសំលាប់ ត្រូវបានពួកវាប្រមូលពីគ្រប់កន្លែងដូចជា មកពីសមរភូមិ ឧត្តុង សមរភូមិកំពង់ឆ្នាំង រួមទាំងប្រជាជនមកពីគ្រប់កន្លែង ។ ប្រជាជនដែលត្រូវយកទៅសំលាប់ត្រូវបានពួកខ្មែរក្រហមចោទថាបានបំរើខ្មាំង ។ មិនត្រឹមតែមនុស្សធំទេ សូម្បីតែកូនក្មេងដែលមិនទាន់ដឹងក្តី ក៏ពួកវាយកទៅសំលាប់ដែរ ដោយក្មេងៗទាំងនោះបានរត់ទៅតាមឪពុកម្តាយដែលពួកខ្មែរក្រហមយកទៅសំលាប់ ។ វិធីដែលនាំមនុស្សយកទៅសំលាប់ គឺពួកខ្មែរក្រហមបានប្រាប់ថា " អង្គការអោយបងប្អូនទៅរៀនសូត្រ " ។ តាមសម្តី **ប៊ិន ម៉េត** ថា គ្រាន់តែឮពាក្យថា "អង្គការអោយរៀនសូត្រ" មនុស្សម្នាបានដណ្តើមគ្នាចង់ទៅរៀនសូត្រ ។ នៅពេលដែលពួកខ្មែរក្រហមត្រឡប់ពីនាំប្រជាជនទៅរៀនសូត្រវិញ **ប៊ិន ម៉េត** ថា គាត់បានឃើញ ពួកខ្មែរក្រហមត្រឡប់មកក្នុងភូមិដោយមានកាន់ចប កន្ត្រៃ មុង ខោអាវ កញ្ចាស់ៗ ។ ទាក់ទិននឹងការបញ្ជា អោយយកទៅរៀនសូត្រ **ប៊ិន ម៉េត** និយាយថា **តាសារិន** ជាអ្នកបញ្ជា ហើយ **តាសារិន** នេះមានអំណាចធំណាស់ក្នុងតំបន់នោះ ព្រោះគាត់ជាប្រធានសន្តិសុខក្នុងតំបន់នោះរួមជាមួយឈ្មោះ **ណៃ** ឈ្មោះ **តាឡាំង** អនុប្រធាន និងលេខាកត់ត្រាឈ្មោះ **គួន** ។ **តាសារិន** មានប្រពន្ធឈ្មោះ **តុំ** ។ ពួកខ្មែរក្រហមមុនយកមនុស្សទៅសំលាប់ ពួកវាបានផឹកទឹកត្នោតជូរអោយស្រវឹង ឬក៏ផឹកស្រា ដែលតាមសម្តីសាក្សី **ប៊ិន ម៉េត** ថា ពួកវាបានដាក់ទឹកត្នោតជូរ ឬស្រាតាមខ្លួន ពេលពួកវាយកមនុស្សទៅសំលាប់ម្តងៗ ។ ចំពោះស្ត្រីភេទវិញ **ប៊ិន ម៉េត** និយាយថា ពួកខ្មែរក្រហមបានប្រមូលនារីៗមកពីគ្រប់មជ្ឈដ្ឋាន យកមកដាក់កន្លែងវា បើពួកវាយកនារីណាទៅសំលាប់ពួកវាបានរំលោភសប្បាយអោយអស់ចិត្ត ហើយទើបពួកវាយកនារីនោះទៅសំលាប់ចោលជាក្រោយ ដែលរហូតដល់សព្វថ្ងៃនេះគ្មាននារីណាមួយក្នុងចំណោមនារីទាំងអស់នោះនៅរស់រានមានជីវិតឡើយ ។ លោកតា **ប៊ិន ម៉េត** មានបងប្អូន ៣នាក់ និងបងប្អូនជីដូនមួយ ៥នាក់ ត្រូវបានស្លាប់ក្នុងរបបប៉ុលពត ។ មុននឹងបញ្ចប់ការសំភាសជាមួយគាត់ **ប៊ិន ម៉េត** បានប្រាប់ឈ្មោះសាក្សីមួយទៀត ដែលក្នុងជំនាន់នោះបានរស់នៅភូមិជំទាវជ្រែងដែរ គឺលោកតាឈ្មោះ **តិល** ។ ក្នុងពេលដែលក្រុមយើងដើរចូលក្នុងព្រៃត្រពាំងអំពិលនោះ មានការអមដំណើរដោយលោកអភិបាលស្រុករង **ចាន់ វឿន** សាក្សី **ប៊ិនម៉េត**. **អួន ចាម**. មេភូមិជំទាវជ្រែង **ស្វាយ ថេង** ប្រធានកងជីវពលឃុំក្រាំងល្វា ។ ប៉ុន្តែអ្នកដែលស្គាល់ផ្លូវច្បាស់គឺលោកមេភូមិ ជំទាវជ្រែង **អួន ចាម** ។

មកដល់ភូមិជំទាវជ្រែងវិញ យើងបានទៅសំភាសលោកតា **តិល** ដែល **ប៊ិន ម៉េត** បានចង្អុលបង្ហាញ ។ ជាសំណាងល្អយើងបានជួបតា **តិល** តាមការគ្រោងទុក ហើយបានសំភាសដូចមានខ្លឹមសារខាងក្រោម :

## សាក្សីទី ២

ឈ្មោះ **គីម តិល** អាយុ ៦៩ឆ្នាំ មានដើមកំណើតកើតជានៅ ភូមិជំទាវជ្រែង ឃុំក្រាំងល្វា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ បច្ចុប្បន្ននៅភូមិឃុំដដែល ប៉ុន្តែស្រុកកំពង់ត្រឡាច ត្រូវដូរមកដាក់ឈ្មោះស្រុកសាមគ្គីមានជ័យ ដូចដែលបានអធិប្បាយពីខាងដើមនៃការបង្កបង្កើតស្រុកថ្មីនេះ ។

ក្នុងជំនាន់ប៉ុលពត តា **គីម តិល** ធ្លាប់ធ្វើជាមេកង ដែលក្តាប់មនុស្សពី ៥ ទៅ ៦នាក់ ក្នុងការភ្ជួររាស់កាប់គាស់ដីស្រែ ។ រាល់ការងារផ្សេងៗ ពួកខ្មែរក្រហមជាអ្នកកំណត់អោយក្រុមរបស់គាត់ធ្វើ គាត់ពុំមានសិទ្ធិចាត់ចែងការងារអ្វីតាមចិត្តរបស់គាត់បានទេ ។ ទាក់ទងនឹងការសំលាប់មនុស្ស តា **គីម តិល** និយាយថាពួកខ្មែរក្រហមបានចាប់មនុស្សយកមកពីគ្រប់ទីកន្លែងយកទៅសំលាប់ គាត់បានឃើញពួកខ្មែរក្រហមចាប់មនុស្សនេះដោយផ្ទាល់ភ្នែក ។ គាត់ធ្លាប់បានឃើញពួកខ្មែរក្រហមចាប់ចងមនុស្សដោយដាក់ដៃទៅក្រោយ ហើយបណ្តើរយកទៅសំលាប់ចោល ដោយបណ្តើរចេញពីភូមិដែលគាត់រស់នៅ ឆ្ពោះទៅព្រៃខាងត្បូងភូមិ។ បើតាមជាក់ស្តែងព្រៃខាងត្បូងភូមិ ដែលតា **គីម តិល** និយាយ គឺជាកន្លែងដែលក្រុមយើងបានចុះទៅដល់គឺព្រៃត្រពាំងអំពិល ព្រោះព្រៃនេះស្ថិតនៅទិសខាងត្បូងភូមិជំទាវជ្រែង ចំងាយប្រហែល ៥គីឡូម៉ែត្រ ដែលគាត់រស់នៅសព្វ ថ្ងៃ។ តា **គីម តិល** រាយការណ៍ថា កាលជំនាន់នោះកម្មាភិបាលឃុំ មានឈ្មោះ **តាចេង. តាគី** ហើយគាត់ដែលបាន ធ្វើជាមេកងក្នុងជំនាន់នោះក៏ដោយសារ **តាចេង តាគី** នេះឯងជាអ្នកចាត់តាំងគាត់ ។ តា **គីម តិល** ពុំសូវបានរាយការណ៍អ្វីច្រើនប៉ុន្មានទេ ភាគច្រើនគាត់ឆ្លើយថា " មិនដឹង " ដូច្នេះយើងក៏បញ្ចប់ការសំភាសន៍ជាមួយគាត់ ហើយយើងបន្តទៅរកសាក្សីម្នាក់ទៀត តាមការរាយការណ៍របស់លោកអភិបាលស្រុករង គឺឈ្មោះ យាយ **ណាំ**។ ឆ្លងតាមការសំភាសន៍យាយ **ណាំ** មានឈ្មោះពិត **កុល ណាំ** អាយុ ៦៤ឆ្នាំ មានស្រុកកំណើតនៅ ភូមិក្រាំងល្វា ឃុំក្រាំងល្វា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ បច្ចុប្បន្ន លោកយាយ នៅក្នុងភូមិឃុំដដែល ដោយដូរតែស្រុកគឺស្រុកសាមគ្គីមានជ័យ ។ ពួកខ្មែរក្រហមបានចាប់ប្តីរបស់គាត់យកទៅបាត់តាំងពីឆ្នាំ ១៩៧៣ ហើយពួកវាបានរឹបអូសគោរបស់គាត់ យកដីស្រែ យករទេះរបស់គាត់ ។ ក្រោយមកពួកខ្មែរក្រហមបានយកគាត់មកដាក់អោយរស់នៅក្នុងភូមិជំទាវជ្រែង អស់រយៈពេល ៩ខែ ។ ក្រោយមកទៀតពីឆ្នាំ ១៩៧៥-១៩៧៩ យាយ **ណាំ** ត្រូវបានផ្លាស់មកនៅភូមិក្រាំងល្វា ឃុំក្រាំងល្វា រហូតដល់សព្វថ្ងៃ ដោយអោយដើរដាំបាយតាមកងលើកទំនប់ ។ គាត់ថាខ្មែរក្រហមអោយប្រជាជនក្នុងភូមិហូបបាយ បានតែ២ខែទេ គឺក្នុងខែដែលច្រូតស្រូវ ហើយក្រៅពីនោះគឺហូបបបរ ដែលជួនកាល ១កំប៉ុងអង្ករ ហូបគ្នាពីរនាក់ ឬ បីនាក់ តាមការដែលពួកវានិយាយថាមានអង្ករ ឬ ខ្វះអង្ករ ។ តាមពិតនៅក្នុងភូមិគាត់ក្នុងសម័យ **ប៉ុល ពត** ប្រជាជនធ្វើស្រែបានផលល្អណាស់ ប៉ុន្តែខ្មែរក្រហមមិនអោយប្រជាជនហូបឆ្អែតទេ ដោយយកលេសថា ទុកស្រូវសំរាប់ដូរយកសំភារៈផ្សេងៗមកប្រើប្រាស់វិញ ដូចជាចប ក្រណាត់ ។ លោកយាយនិយាយថា ពួកខ្មែរ

ក្រហមបានយកមនុស្សទៅសំលាប់ចោល ដោយចោទថាខ្មាំង ប៉ុន្តែយាយ **ណាំ** មិនបានដឹងថា តើពួកវាយកមនុស្សទៅសំលាប់នៅកន្លែងណាច្បាស់ទេ ។ ក្នុងកងរបស់យាយ **ណាំ** គឺមានសុទ្ធតែស្រីៗ ប៉ុន្តែអ្នកគ្រប់គ្រងបែរជាប្រុសទៅវិញ ហើយយាយ **ណាំ** ថា គាត់មិនបានចាំឈ្មោះ អ្នកគ្រប់គ្រងក្នុងក្រុមរបស់គាត់នោះឡើយ ផ្ទុយទៅវិញ គាត់បែរជាស្គាល់ឈ្មោះអ្នកក្តាប់រួម គឺឈ្មោះ តា **សារិន** ដូចដែល **មិន ម៉េត** រាយការណ៍ពីខាងលើដែរ ។ ដោយសំភាសន៍រាល់សាក្សីដែលយើងចង់ជួបហើយ យើងក៏បានធ្វើដំណើរវិលត្រឡប់មកស្នាក់នៅទីរួមខេត្តកំពង់ឆ្នាំងវិញ ដើម្បីត្រៀមលក្ខណៈចុះទៅស្រាវជ្រាវទីតាំងផ្សេងទៀតស្ថិតនៅភូមិដីស្រុត ឃុំស្វាយជុក ក្នុងស្រុកដដែល នៅថ្ងៃបន្ទាប់ ។

ដូចការគ្រោងទុករបស់ក្រុមផែនទី នៅព្រឹកថ្ងៃទី ១១ ខែ ឆ្នាំ ដដែល ប្រហែលម៉ោងជាង ៦ យើងបានធ្វើដំណើរចេញពីទីរួមខេត្តកំពង់ឆ្នាំងម្តងទៀត ឆ្ពោះមកផ្ទះលោកប្រធានមន្ទីរស្រុកសាមគ្គីមានជ័យឈ្មោះ **កៅ ហ៊ុន** ដែលស្ថិតនៅម្តុំសាលាលេខ ៥ ។ ដូចចិត្ត ពេលមកដល់មុខផ្ទះ យើងឃើញលោកប្រធានមន្ទីរស្រុកឈរចាំនៅពីមុខផ្ទះជាស្រេច រួចហើយគាត់ក៏ធ្វើដំណើរបន្តមកដល់ផ្សារត្រាចជាមួយយើងដើម្បីជូនយើងទៅជួបលោកមេឃុំស្វាយជុក ឱ្យលោកមេឃុំជូនយើងបន្តរហូតដល់ទីតាំងសំលាប់និងទីតាំង **គុកព្រៃដីរ ស្រុត** ដូចដែលឈ្មោះ **គីម ពន** បានរាយការណ៍ថ្ងៃទី ៩ មិថុនា ឆ្នាំ ១៩៩៩ ។ ឯចំពោះផ្លូវដែលត្រូវទៅទីតាំងនោះ យើងមិនបានរៀបរាប់ក្នុងរបាយការណ៍នេះទេ តែយើងសូមភ្ជាប់គំនូសសញ្ញាក្នុងរបាយការណ៍ជាជំនួសវិញ ។ ពេលទៅដល់ផ្ទះ តា **អ៊ុក យុន** យើងបានជួបតាមេឃុំនៅទីនោះ ដែលកំពុងរង់ចាំយើងនៅតាមបណ្តោយផ្លូវដែលត្រូវធ្វើដំណើរឆ្ពោះទៅព្រៃដីស្រុត ។ ក្រុមយើងបានធ្វើដំណើរទាំអស់គ្នាតាមរថយន្តបន្តទៅទៀត រហូតដល់វត្តច្រកសង្កែ ទើបយើងឈប់ឡាននៅទីនោះ ហើយលោកប្រធានមន្ទីរស្រុកសាមគ្គីមាន ជ័យបានទៅអញ្ជើញ លោកប្រធានភូមិច្រកសង្កែ ឈ្មោះ **គ្រួច គ្រួយ** ដើម្បីអោយគាត់នាំផ្លូវក្រុមយើងចុះ ទៅពិនិត្យដល់ទីតាំង **គុកព្រៃដីរស្រុត** ។ ចេញដំណើរដោយថ្មើរជើង ឆ្ពោះទៅព្រៃខាងក្រោយវត្តច្រកសង្កែ ទិសខាងត្បូង ចំងាយប្រហែល ២៥០០ម៉ែត្រ ពីវត្តក្រុមយើងបានទៅដល់ទីតាំងគុកក្នុងជំនាន់ខ្មែរក្រហមកាន់កាប់ ។ ទំរាំដល់ទីតាំងនេះ យើងត្រូវធ្វើដំណើររុកព្រៃក្រាស់ ក្នុងចំងាយផ្លូវស្មុគស្មាញ ដោយសារផ្លូវពិបាកចំណាំ និងមានកូនឈើតូចដុះជុំជិត ។ ប្រសិនបើគ្មានអ្នកស្រុកនៅទីនោះ ឬក៏គ្មានលោកប្រធានភូមិជូនដំណើរយើងទេ ប្រហែលជាយើងពិបាកនឹងរកទីតាំងគុកព្រៃដីរស្រុតមិនខាន ។ ពេលក្រុមយើងទៅដល់ទីតាំងនោះសាក្សីដែលជាមេឃុំស្វាយជុកឈ្មោះ **អុក ឡូន** បានចង្អុលប្រាប់យើងនូវទីតាំងអាគារស្នាក់នៅរបស់ខ្មែរក្រហមដែលមានភារកិច្ចមើលការខុសត្រូវរួមក្នុងតំបន់នេះ ហើយដែលអាគារនេះមានទំហំទទឹងប្រហែលជាង ៤ម៉ែត្រ បណ្តោយប្រវែងជាង ៨ម៉ែត្រ ប្រក់ក្បឿង ដែលបច្ចុប្បន្នបាក់បែកគ្មានអ្វីសេសសល់ក្រៅតែពីកំទេចក្បឿងតែប៉ុណ្ណោះ ។ បន្ទាប់មកក្រុមយើងបានបន្តទៅមើលទីតាំងគុក ដែលមានចំងាយប្រហែល ៥០ម៉ែត្រ ពីអាគារស្នាក់នៅរបស់

ខ្មែរក្រហមជំនាន់នោះ ។ ទីតាំងគុកនេះ ពុំមានសេសសល់អ្វីបន្តិចបន្តួចសោះគ្រាន់ទុកជាសំអាង ក្រៅពីទីលានដីរាបស្មើមានដុះស្មៅ និង មានដើមឈើមួយដ៏ធំគ្រាន់ទុកជាចំណាំ រួមផ្សំនឹងការបង្ហាញប្រាប់ជាពាក្យសម្តីរបស់សាក្សីប៉ុណ្ណោះ ។ ឆ្លៀតឱកាសនោះ យើងបានធ្វើការសំភាសមេឃុំស្វាយជុក ឈ្មោះ **អ៊ុក ឡួន** ដែលខ្លឹមសារសំភាសមានដូចខាងក្រោយ ។

__**សាក្សី**__ : ឈ្មោះ **អ៊ុក ឡួន** អាយុ ៦១ឆ្នាំ បច្ចុប្បន្នជាមេឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ គាត់ធ្វើជាមេឃុំតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ។ **អ៊ុក ឡួន** មានស្រុកកំណើតនៅ ភូមិតាំងក្រងឃុំស្វាយជុក ស្រុកកំពង់ត្រឡាច ដែលឥឡូវប្រែក្លាយមកជាស្រុកសាមគ្គីមានជ័យ ។ ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ ៧៩ គាត់ជាប្រជាជនធម្មតារស់នៅក្នុង ភូមិតាំងក្រង ឃុំស្វាយជុក ស្រុកកំពង់ត្រឡាចលើ ( ស្រុក១២) តំបន់៣២ ។ **អ៊ុក ឡួន** និយាយថា គាត់បានជួបប្រទះឃើញគុកនៅក្នុងព្រៃដីស្រុតនេះ ដោយសារគាត់ពេលនោះត្រូវបានប្រើអោយដឹកអាចម៍គោតាមរទេះគោ យកទៅដាក់នៅក្បែរគុកនោះ ។ គុកនោះធ្វើពីឈើប្រក់ស្លឹក ដោយគ្មានជញ្ជាំង ដែលមានទទឹងប្រវែងប្រមាណ ៧ម៉ែត្រ និង បណ្តោយប្រមាណ ២១ម៉ែត្រ ហើយដាក់អ្នកទោសរាប់រយនាក់ ។ អ្នកទោសទាំងនោះត្រូវបានពួកអ្នកយាមគុកដាក់ខ្នោះជើងទាំងពីរតំរៀបជាពីរជួរ ដោយដេកយកជើងដែលជាប់ខ្នោះដាក់ទល់គ្នា ។ តាមសំដីគាត់ដែលបន្ថែមក្រោយទៀតថា អ្នកទោសដែលចាត់ទុកថាមានទោសមធ្យម ភាគច្រើនជាទាហ៊ានរបបលន់ណុលដែលមានដាក់ខ្នោះជើងដែរ ប៉ុន្តែពេលចេញទៅធ្វើការ ត្រូវចេញទៅធ្វើទាំងជើងជាប់ខ្នោះ ដែលអ្នកទោសទាំងនោះដើរលោត១ របៀបដូចសត្វកង្កែប ហើយមានអ្នកទោសទាំងអស់នេះខ្លះត្រូវខ្មែរក្រហមបង្ខំអោយធ្វើការធ្ងន់រហូតទាល់តែស្លាប់ក៏មាន ។ ចំណែកអ្នកទោសមួយប្រភេទទៀត ជាអ្នកទោសដែលត្រូវបានចាត់ទុកថាមានទោសធ្ងន់ ដែលអ្នកទាំងនេះភាគច្រើនត្រូវខ្មែរក្រហមចោទថា ជាខ្មែរស គឺជាប្រជាជនដែលមិនពេញចិត្តនឹងរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហម ហើយចង់ចេញតស៊ូរើបំរះ។ អ្នកទោសប្រភេទនេះត្រូវបានហៅថា អ្នកទោសធ្ងន់ ដែលត្រូវជាប់ខ្នោះជើងទាំងពីរនៅក្នុងគុក ដោយមិនអនុញ្ញាតិឱ្យចេញទៅធ្វើការងារនៅខាងក្រៅគុករហូតទាល់តែស្លាប់ខ្លួនទាំងជើងជាប់ខ្នោះ ។ អ្នកទោសប្រភេទនេះបើបានចាប់មកគឺចាប់ទាំងខ្សែស្រឡាយ ទាំងគ្រួសារ តែម្តង គ្មានសល់ម្នាក់ឡើយ ។ តាមសំដីលោកមេឃុំស្វាយជុក **អ៊ុក ឡួន** ថា អ្នកទោសនៅទីនេះមិនសូវត្រូវបានពួកខ្មែរក្រហមសំលាប់ទេ គឺភាគច្រើនអ្នកទោសស្លាប់ដោយអត់បាយ ស្លាប់ដោយដាក់ខ្នោះ រហូតដល់ស្លាប់ក្នុងគុក ស្លាប់ដោយបង្ខំឱ្យធ្វើការធ្ងន់ស្លាប់ដោយឈឺថ្កាត់ គ្មានថ្នាំព្យាបាល ។ សាកសពនៃអ្នកទោសទាំងអស់នោះត្រូវបានពួកខ្មែរក្រហមបញ្ជាអោយអ្នកទោសដែលនៅរស់នៅទីគុក អោយអូសសពនោះទៅដាក់ក្នុងអន្លង់សំរាប់ដាំដើមដូង ដែលជូនកាលមួយអន្លង់ត្រូវដាក់សពពីរ ជួនកាលសពមួយទាំងមូល ជួនកាលកាត់សពជាពីរកំណាត់ ។ ទាក់ទងរឿងនេះដែរ លោកប្រធានភូមិច្រកសង្កែ ឈ្មោះ **គ្រួច គ្រួយ** ក៏បានប្រាប់យើងដូចលោកមេឃុំស្វាយជុក

ឈ្មោះ **អ៊ុក ឡូន** ដែរ គ្រង់ថា សពអ្នកទោសត្រូវយកទៅដាក់ក្នុងរណ្ដៅសំរាប់ ដាំដើមដូង ។ ទាំងមេភូមិទាំងមេឃុំ បានចង្អុលប្រាប់យើងនូវវាលស្មៅដែលមានស្នាមរណ្ដៅដូង ដែលស្ទើរតែរលប់បាត់អស់ ហើយនិយាយថា ក្នុងទីវាលមួយនេះមានដើមដូងប្រហែលជា ២០០ ដើម ដែលរហូតមកដល់ពេលនេះបាត់អស់ហើយ ដោយសារទី១ ប្រជាជននៅជុំវិញតំបន់នោះបានមកគាស់ដូងយកទៅដាំនៅតាមផ្ទះ របស់ពួកគេដូចជាមេឃុំបានគាស់ដូងយកទៅដាំនៅផ្ទះគាត់បាន ៣ដើម ដែលបច្ចុប្បន្ននេះ ដូងនោះនៅរស់នៅឡើយ ។ ទី២ ពួកខ្មែរក្រហមដែលនៅសេសសល់ក្នុងជំនាន់ក្រោយរំដោះឆ្នាំ៧៩ បានកាប់យកដើមដូងហូប (យកបណ្ដូលដូងដែលនៅចុងនៃដើមដូង) ។ តាមការប៉ាន់ស្មានរបស់សាក្សីថា វាលដែលត្រូវដាំដើមដូង អាចមានទំហំប្រមាណមួយគីឡូម៉ែត្របួនជ្រុង ក្នុងវាលនេះទៀតសោត មិនដាំតែដើមដូងទេ គឺមានដាំដំឡូងមីដែលត្រូវយកសពដាក់ធ្វើជាជីដីផងដែរ ។ សាក្សីខាងលើចុងក្រោយបានបញ្ជាក់ប្រាប់ឈ្មោះអ្នកទទួលខុសត្រូវនៅក្នុងគុកព្រៃដីរស្រុត ដូចមានឈ្មោះខាងក្រោម ៖

ឈ្មោះ **អ៊ីុល** ជាប្រធានគុក បន្ទាប់មកឈ្មោះ **សួន អែម** និង **សឿន** ដែលបច្ចុប្បន្ននេះមាននៅរស់ពីរនាក់ គឺ **អែម** នៅភូមិត្បែងខ្ពស់ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ និងឈ្មោះ **អ៊ីុល** នៅភូមិច្រេស ឃុំច្រេស ស្រុកកំពង់ត្រឡាច ។ បើតាមសំដីឈ្មោះ **អ៊ុក ឡូន** ឈ្មោះ **អែម** ជាជនដៃដល់ដ៏ខ្លាំងក្លាជាងគេនៅក្នុងគុក **ព្រៃដីរស្រុត**នេះ ប៉ុន្តែគាត់ប្រាប់យើងដោយមានការភ័យខ្លាច ឈ្មោះ **អែម** មករករឿងគាត់ គាត់បានឱ្យយើងកុំប្រាប់ឈ្មោះ **អែម** ថា គាត់ជាអ្នកប្រាប់អោយសោះ ប្រសិនបើពេលយើងចង់ទៅសំភាសជាមួយ ឈ្មោះ **អែម** ។ ដោយមានការថតរូបយកទីតាំងគុកដីរស្រុត ថតរូបសាក្សីប្រើម៉ាស៊ីន GPS រួចស្រេចអស់ហើយ ក្រុមយើងបានធ្វើដំណើរចេញពីព្រៃនោះ ឆ្ពោះមកកាន់ទីធ្លាវត្តច្រកសង្កែវិញ ហើយបានបន្តដំណើរត្រឡប់វិញ ដល់ប្រហែលជាពាក់កណ្ដាលផ្លូវ ដែលស្ថិតក្នុងភូមិត្រពាំងម្ទេស ក្រុមយើងបានចុះទៅពិនិត្យកន្លែងសំលាប់មនុស្សមួយកន្លែង ដែលតាមការបង្ហាញប្រាប់របស់សាក្សីឈ្មោះ **អ៊ីុក យុន** អាយុ ៦០ឆ្នាំ ភេទ ប្រុស បច្ចុប្បន្ន នៅភូមិត្រពាំងម្ទេស ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ។

តាមការបង្ហាញប្រាប់របស់សាក្សី **អ៊ីុក យុន** ទីតាំងសំលាប់មនុស្សនេះមានឈ្មោះថា **ព្រៃតាគុច** ដែលស្ថិតនៅខាងជើងភូមិត្រពាំងម្ទេស ហើយមានចំងាយប្រហែល ១៥០ម៉ែត្រ ចេញពីផ្លូវ ។ សាក្សី **អ៊ីុក យុន** និយាយថា ក្រៅពីគាត់ ប្រជាជនក្នុងភូមិនេះនរណាក៏ដឹង និងស្គាល់ទីតាំងនេះដែរ ។ ទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងនៅទីនោះ លោក **អ៊ីុក យុន** ប្រាប់យើងថា ទីតាំងនេះពួកខ្មែរក្រហមយកធ្វើជាកន្លែងសំលាប់ជីវិតមនុស្ស ក្នុងឆ្នាំ ១៩៧៥ ដែលមានរណ្ដៅសាកសពប្រមាណ ១០ រណ្ដៅ មានទំហំ ៥ ម៉ែត្រ បួនជ្រុង ក្នុងជំរៅ ១ម៉ែត្រ ។ មុនដំបូងពួកខ្មែរក្រហមបានប្រមែប្រមូលមនុស្សគ្រប់ទីកន្លែងយកមកដាក់ក្នុងភូមិត្រពាំងម្ទេស បន្ទាប់មកពួកវាបានយកមនុស្សនោះជាក្រុម១ ឬ គ្រួសារ១ មកសំលាប់នៅក្នុងទីតាំងព្រៃតាគុចនេះ ដែលមុននឹងសំលាប់ ពួកខ្មែរក្រហមបានសំរាតយកខោអាវពីខ្លួនប្រជាជនទាំង

នោះ ហើយដឹកយកខោអាវនោះមកទុកក្នុងភូមិវិញ ។ ការកាប់សំលាប់របស់ខ្មែរក្រហមនៅក្នុងព្រៃតាគុច ធ្វើឡើងតែ ៤ ឬ ៥ ប៉ុណ្ណោះ ហើយតាមការប៉ាន់ស្មានរបស់សាក្សីថា មានប្រហែលពី ៣០០ ទៅ ៥០០នាក់ ត្រូវបានពួកសន្តិសុខភូមិសំលាប់នៅទីនោះ ។ ពេលក្រុមយើងចុះទៅទីតាំងព្រៃគុចនេះ យើងឃើញផ្ទាល់ភ្នែកនូវកំទេចឆ្អឹងមនុស្ស និងកំទេចកំទីសំលៀកបំពាក់របស់ជនរងគ្រោះ នៅនឹងគែមរណ្តៅសាកសព ។ ក្រោយពីសំភាសសាក្សីរួចរាល់ហើយ ក្រុមផែនទីរបស់យើងក៏បានធ្វើដំណើរវិលត្រលប់មកភ្នំពេញវិញ ដោយនាំមកនូវភាពជោគជ័យ ដែលពេលប៉ុន្មានឆ្នាំមុនយើងពុំដែលបានចុះទៅដល់ទាល់តែសោះ ចំពោះទីតាំងសំលាប់ និង ទីតាំងគុក នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

**<u>សន្និដ្ឋាន :</u>**

រយៈ៣ថ្ងៃ ដែលក្រុមផែនទីយើងបានចុះទៅស្រុកសាមគ្គីមានជ័យ ក្នុងខេត្តកំពង់ឆ្នាំង គឺបានទទួលលទ្ធផលល្អប្រសើរ ដោយហេតុថា យើងបានចុះដល់ទីតាំងកន្លែងកើតហេតុ ៣កន្លែង គឺ ព្រៃត្រពាំងអំពិល ក្នុងភូមិជំទាវជ្រែង ព្រៃដីស្រុត ក្នុងភូមិច្រកសង្កែ និងព្រៃតាគុច ក្នុងភូមិត្រពាំងម្ទេស ព្រមទាំងប្រមូលបានពតិមានល្អៗពីសាក្សីដែលធ្លាប់រស់នៅក្បែរកន្លែងទាំង ៣ និងធ្លាប់ជាប់គុកនៅក្នុងកន្លែងនោះទៀតផង ។ម្យ៉ាងវិញទៀត ទាំងរដ្ឋអំណាចមូលដ្ឋាននៅទីនោះ ទាំងសាក្សី សុទ្ធតែបានជួយសហការគ្នាល្អដើម្បីអោយក្រុមយើងងាយស្រួលក្នុងការធ្វើការងារនេះ ។ ចំពោះរបាយការណ៍នេះ យើងគិតថាវាមិនទាន់គ្រប់គ្រាន់ទេ ព្រោះថាយើងពុំបានចុះទៅធ្វើការនៅទីតាំងជ្រលងតាពុច ដែលជាទីតាំងសំលាប់មនុស្សក្នុងឆ្នាំ១៩៧៥ ដោយសាររយៈពេលខ្លី ដែលនៅសល់ និងមេឃរកកល់នឹងភ្លៀង ។ម្យ៉ាងទៀតក្រុមយើងពុំបានទៅរកជួបសំភាសន៍ជាមួយឈ្មោះ **អែម** ដែលតាមសាក្សីថាឈ្មោះនេះជាជនដែដល់នៅក្នុងគុកព្រៃដីស្រុត ដោយសារតាមលោកប្រធានមន្ទីរស្រុកឈ្មោះ **កៅ ហ៊ុន** ថាត្រូវប្រាប់មេឃុំដែលជននោះរស់នៅជាមុនសិន ដើម្បីងាយស្រួលដល់ក្រុមការងារយើងជួបសំភាសន៍ ព្រោះថាជនរូបនេះមិនងាយនឹងឱ្យនរណាម្នាក់ចូលជួបសួរនាំរឿងរ៉ាវក្នុងរបប **ប៉ុល ពត** ឡើយ ។យកល្អយើងគួរទៅជួបសំភាសន៍ជាមួយឈ្មោះ **អែម** អោយបាន ប្រសិនបើមានឱកាស ។

# ប្លង់ទីតាំងរណ្តៅ

( Prey Trapeang Ampil )




- ចំងាយពីច្រកចូលទៅទីតាំងរណ្តៅ Prey Trapeang Ampil ប្រហែលជាង 17 Km
- ចំងាយពីភូមិ Chumteav Chreng Thmei ទៅទីតាំងរណ្តៅ Prey Trapeang Ampil ប្រហែល 2 Km ( ក្នុងព្រៃ )

# ប្លង់ទីតាំងរណ្តៅ

Prey Damrei Srot

**( Prey Damrei Srot )**




❋ ចំងាយពីច្រកចូលទៅទីតាំងរណ្តៅ Prey Damrei Srot ប្រហែលជាង 19 Km

❋ ចំងាយពីច្រកចូលទៅទីតាំងរណ្តៅ Prey Takuch ប្រហែល 1950 m

# ប្លង់ទីតាំងមន្ទីរស្រុក

## ( SMAKIMEANCHEY )




- ចំងាយពីច្រកចូលឆ្ពោះទៅកាន់មន្ទីរស្រុកសាមគ្គីមានជ័យប្រហែល 12 Km
- ចំងាយពី P.Penh ទៅផ្សារស្ពានពោធិ៍ ប្រហែលជា 50 Km .

# ប្លង់ទីតាំងមន្ទីរស្រុក

## ( SMAKIMEANCHEY )




- ចំងាយពីច្រកចូលឆ្ពោះទៅកាន់មន្ទីរស្រុកសាមគ្គីមានជ័យប្រហែល 12 Km
- ចំងាយពី P.Penh ទៅផ្សារស្ពានពោធិ៍ ប្រហែលជា 50 Km .